# ព្រះរាជក្រឹត្យ

នស/រកត/០៩១៤/១១៣៦

## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃ
## ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលសរសេរជាអក្សរកាត់ថា **ក.ជ.វ.ប.** ដើម្បីជំរុញកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅកម្ពុជាឲ្យមានការរីកចម្រើនដូចបណ្តាប្រទេសជឿនលឿនក្នុងតំបន់និងក្នុងសកលលោក។

## ជំពូកទី២
## សមាសភាពរបស់ ក.ជ.វ.ប.

**មាត្រា២ .-**

**ក.ជ.វ.ប.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងផែនការ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប សមាជិក
- អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប សមាជិក
- អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា១រូប សមាជិក
- អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប សមាជិក
- តំណាងស្ថាប័នសិក្សាស្រាវជ្រាវ១ចំនួន សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា១រូប សមាជិក
- អគ្គលេខាធិការ **ក.ជ.វ.ប.** លេខាធិការ។

សមាសភាពជាក់ស្តែងរបស់ **ក.ជ.វ.ប.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ ក.ជ.វ.ប.

**មាត្រា៣ .-**

**ក.ជ.វ.ប** មានតួនាទីភារកិច្ចដូចខាងក្រោម៖

- រៀបចំតាក់តែងសេចក្តីព្រាងនិងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- កំណត់តម្រូវការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលស្នើឡើងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជនដែលពាក់ព័ន្ធ
- ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជា ឬរបស់អគ្គលេខាធិការដ្ឋាន **ក.ជ.វ.ប**
- កៀរគរជំនួយនិងការគាំទ្រធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដែលជាតម្រូវការនៃស្ថាប័នឬអង្គភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- កំណត់អាទិភាពការងារវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- បញ្ជ្រាបការយល់ដឹង ការឲ្យតម្លៃ និងការចែករំលែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ជំរុញនិងលើកទឹកចិត្ត ការចូលរួម ការលើកស្ទួយក្នុងកិច្ចអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាពីគ្រប់មជ្ឈដ្ឋាន/.

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប សមាជិក
- អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប សមាជិក
- អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា១រូប សមាជិក
- អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប សមាជិក
- តំណាងស្ថាប័នសិក្សាស្រាវជ្រាវ១ចំនួន សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា១រូប សមាជិក
- អគ្គលេខាធិការ **គ.ជ.វ.ប.** លេខាធិការ។

សមាសភាពជាក់ស្តែងរបស់ **គ.ជ.វ.ប.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ជ.វ.ប.

**មាត្រា៣ .-**

**គ.ជ.វ.ប** មានតួនាទីភារកិច្ចដូចខាងក្រោម៖

- រៀបចំតាក់តែងសេចក្តីព្រាងនិងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- កំណត់តម្រូវការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលស្នើឡើងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជនដែលពាក់ព័ន្ធ
- ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជា ឬរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប**
- កៀរគរជំនួយនិងការគាំទ្រធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដែលជាតម្រូវការនៃស្ថាប័នឬអង្គភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- កំណត់អាទិភាពការងារវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- បញ្ជ្រាបការយល់ដឹង ការឲ្យតម្លៃ និងការចែករំលែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ជំរុញនិងលើកទឹកចិត្ត ការចូលរួម ការលើកស្ទួយក្នុងកិច្ចអភិវឌ្ឍ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាពីគ្រប់មជ្ឈដ្ឋាន/

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

- កំណត់គោលការណ៍អភិវឌ្ឍធនធានមនុស្សដើម្បីបម្រើតម្រូវការនិងការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងគម្រោងកម្មវិធីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ហើយធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.វ.ប.

**មាត្រា៤ .-**

**គ.ជ.វ.ប.** ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ជ.វ.ប.** អាចប្រជុំជាវិសាមញ្ញបាន។

សមាជិក **គ.ជ.វ.ប.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ឬអនុប្រធានដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

ប្រធាន **គ.ជ.វ.ប.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកឯកទេសដែលពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជន ចូលរួមផ្តល់យោបល់ក្នុងករណីចាំបាច់។

**គ.ជ.វ.ប.** អាចមានទីប្រឹក្សាបច្ចេកទេសនិងអ្នកជំនាញការជាតិ អន្តរជាតិមួយចំនួនតាមការចាំបាច់។

**គ.ជ.វ.ប.** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែកដែលមានគំរូភ្ជាប់ជាឧបសម្ព័ន្ធ។

បែបបទនៃការប្រជុំរបស់ **គ.ជ.វ.ប.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

**មាត្រា៥ .-**

**គ.ជ.វ.ប.** ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ដែលមានទីតាំងនៅក្រសួងផែនការ។

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.វ.ប.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.វ.ប.** ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា៦ .-**

ត្រូវបានបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជាចំណុះឲ្យ **ក.ជ.ទ.ប.** ដើម្បីជួយការងារបច្ចេកទេស។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាកម្ពុជានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា៧ .-**

ការចំណាយសម្រាប់ដំណើរការរបស់ **ក.ជ.ទ.ប.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងផែនការ។

**ក.ជ.ទ.ប.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ២០១៤

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

នស/រកត/០៩១៤/១១៥៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ:១១៦៦ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ឧបសម្ព័ន្ធ

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៤

## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL